# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១០៤៥......សហវ.ពក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## និមុត្តិធានា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

រដ្ឋបាលគយអាចតម្រូវឱ្យតម្កល់នូវនិមុត្តិធានា ដើម្បីធានាការបង់ពន្ធ និងអាករ ឬដើម្បីធានាថាប្រតិវេទន៍ករ និងភាគីទទួលខុសត្រូវផ្សេងទៀតបំពេញនូវ /



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

កាតព្វកិច្ចតាមនីតិវិធីគយ ឬការអនុវត្តច្បាប់ផ្សេងទៀត ស្របតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីគយ ។

**ប្រការ ២.-**

និមុត្តិធានាអាចតម្រូវឱ្យតម្កល់ក្នុងកាលៈទេសៈដូចតទៅ ៖

- ការយកទំនិញចេញពីគយមុនពេលបង់ពន្ធ និងអាករ

- ចរាចរទំនិញក្នុងរង្វង់ ឬធ្វើការកាត់ផ្ទៃនគយក្រោមរបបធ្វងកាត់

- ការប្រកបធុរកិច្ចជាដើងសារគយ ប្រតិបត្តិករឃ្លាំងគយមានផែនកំណត់ និងប្រតិបត្តិករទីកន្លែងសន្និធិគយបណ្ដោះអាសន្ន

- ការនាំចូល និងនាំចេញទំនិញជាបណ្ដោះអាសន្ន

- ការយកទំនិញចេញពីគយ ដោយរង់ចាំសេចក្ដីសម្រេចលើការតវ៉ា ឬលើទំនិញដែលត្រូវបានឃាត់ទុកជាបណ្ដោះអាសន្ន

- កាលៈទេសៈផ្សេងទៀតតាមដែលអាចតម្រូវដោយរដ្ឋបាលគយ ។

**ប្រការ ៣.-**

និមុត្តិធានាអាចមានទម្រង់ជា ៖

- សាច់ប្រាក់ ឬមូលប្បទានប័ត្រដែលមានការបញ្ជាក់ពីធនាគារ

- ប័ណ្ណធានា ឬនិមុត្តិធានា ដែលចេញ ដោយធនាគារ ក្រុមហ៊ុនធានារ៉ាប់រង ឬស្ថាប័នរដ្ឋ និងលិខិតុបករណ៍តាមទម្រង់ផ្សេងទៀតនៃនិមុត្តិធានាដែលមានការយល់ព្រមពីនាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៤.-**

និមុត្តិធានាក្រោមបញ្ញត្តិនៃប្រកាសនេះ អាចត្រូវប្រើប្រាស់ម្ដង ឬច្រើនដងជាបន្តបន្ទាប់ ។ និមុត្តិធានាដែលប្រើប្រាស់ច្រើនដងជាបន្តបន្ទាប់មានន័យថា និមុត្តិធានាដែលត្រូវបានតម្កល់តាមទម្រង់ និងចំនួនទឹកប្រាក់មួយដែលអាចប្រើប្រាស់បានតាមពីររបៀប ៖

- ទឹកប្រាក់នៃនិមុត្តិធានាត្រូវបានកាត់បន្ថយរាល់ពេលបង់ពន្ធ និងអាករនាំចូលម្តងៗ រហូតដល់អស់ទឹកប្រាក់នេះ

- ទឹកប្រាក់នៃនិមុត្តិធានារក្សាដដែលដោយមិនកំណត់ពេលវេលាមួយ ហើយរាល់ពេលបង់ពន្ធ និងអាករនាំចូលពុំមានការកាត់បន្ថយនូវទឹកប្រាក់នេះទេ ។ និមុត្តិធានាដូចនេះ ជាការធានាជាប់លាប់មួយហើយប្រើប្រាស់សម្រាប់ប្រតិបត្តិការដែលមានលក្ខណៈបន្ត ដូចជា ការប្រកបធុរកិច្ចជាជើងសារគយ ប្រតិបត្តិករឃ្លាំងគយមានដែនកំណត់ ប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន ការដឹកជញ្ជូនទំនិញក្រោមការគ្រប់គ្រងរបស់គយ និងនីតិវិធីគយផ្សេងទៀតដែលពន្ធ និងអាករត្រូវបានព្យួរ ។

**ប្រការ ៥.-**

ទឹកប្រាក់និមុត្តិធានាដែលតម្រូវសម្រាប់កាលៈទេសៈនីមួយៗ ត្រូវជាទឹកប្រាក់ដែលគ្រប់គ្រាន់សម្រាប់ធានាកាតព្វកិច្ចពន្ធ និងអាករ ។ នាយកទីចាត់ការគយនិងរដ្ឋាករអាចអនុញ្ញាតឱ្យតម្កល់ទឹកប្រាក់និមុត្តិធានាទាបជាង ដោយផ្អែកលើការវាយតម្លៃហានិភ័យដល់បុគ្គលនានាដែលមានកម្រិតអនុលោមភាពល្អ ឬជាអ្នកប្រើប្រាស់នូវនីតិវិធីនិមុត្តិធានាបានប្រក្រតី និងត្រឹមត្រូវ ។ ទឹកប្រាក់និមុត្តិធានាត្រូវបានគ្រប់គ្រងឃ្លាំមើល និងអាចត្រូវបានកែប្រែដោយរដ្ឋបាលគយ ។

**ប្រការ ៦.-**

នាយកទីចាត់ការគយ និងរដ្ឋាករ អាចលើកលែងការតម្រូវឱ្យតម្កល់និមុត្តិធានាសម្រាប់ប្រតិបត្តិការនានាដែលធ្វើឡើងដោយស្ថាប័នរដ្ឋ ឬក្នុងស្ថានភាពដែលយល់ថាកាតព្វកិច្ចដែលតម្រូវនានាដែលជាយនឹងបំពេញបាន ឬមានហានិភ័យលើចំណូលទាប ។

**ប្រការ ៧.-**

ក្នុងករណីដែលនិមុត្តិធានាត្រូវបានផ្តល់ដើម្បីធានាលើការនាំចេញ និងការនាំចេញទៅវិញនៃទំនិញ នាយកទីចាត់ការគយ និងរដ្ឋាករអាចដោះលែងនូវនៃនិមុត្តិធានា នៅពេលដែលមានសំអាងថា ទំនិញត្រូវបាននាំចេញ ។ សំអាងនេះ រាប់

បញ្ចូលនូវ ប្រតិវេទន៍គយនាំចេញដែលមានបញ្ជាក់ទទួលស្គាល់ពីមន្ត្រីគយមានសមត្ថកិច្ច ឬប្រតិវេទន៍គយនាំចូលដែលមានបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ។ តាមសំណើរបស់ធុរជន នាយកទីចាត់ការគយ និងរដ្ឋាករអាចទទួលយកនូវឯកសារផ្សេងទៀតទុកជាសំអាងនៃការនាំចេញ ដែលរួមមានឯកសារដឹកជញ្ជូន និងវិញ្ញាបនបត្ររបស់មន្ត្រីមានសមត្ថកិច្ចនៃប្រទេសនាំចូលដែលបញ្ជាក់ថា ទំនិញត្រូវបាននាំចូលប្រទេសនោះ ។

**ប្រការ ៨**.-

ប្រសិនបើលក្ខខណ្ឌនិមុត្តិធានាពុំត្រូវបានបំពេញនោះ រដ្ឋបាលគយត្រូវអនុវត្តដូចខាងក្រោម ៖

- ក្នុងករណីដែលមានការធានាជាសាច់ប្រាក់ ឬមូលប្បទានប័ត្រ រដ្ឋបាលគយត្រូវរក្សាទុកមួយផ្នែកនៃនិមុត្តិធានាដែលគ្រប់គ្រាន់សម្រាប់ការបង់ពន្ធ និងអាករ

- ក្នុងករណីដែលមានការធានាជា លិខិតធានារបស់ធនាគារឬប័ណ្ណធានាពីធនាគារ ក្រុមហ៊ុនធានារ៉ាប់រង ឬស្ថាប័នរដ្ឋនោះ រដ្ឋបាលគយត្រូវចាត់វិធានការសមស្របដើម្បីប្រមូលពីបុគ្គលដែលទទួលបាននូវការធានា ។ ប្រសិនបើពុំអាចប្រមូលពន្ធ និងអាករបាន រដ្ឋបាលគយត្រូវទាមទារទៅអ្នកចេញប័ណ្ណធានា ឬធនាគារពាក់ព័ន្ធដែលចេញការធានាឱ្យបញ្ចេញទឹកប្រាក់សម្រាប់បង់ពន្ធ និងអាករ។ ច្បាប់ចម្លងនៃការទាមទារនេះ មួយច្បាប់ត្រូវផ្តល់ជូនបុគ្គលដែលទទួលបាននូវការធានា ។

- ក្នុងករណីដែលមានការធានាជាទម្រង់ផ្សេងទៀត រូបវន្តបុគ្គលដែលទទួលខុសត្រូវចេញការធានា ត្រូវបង់ពន្ធ និងអាករជាបន្ទាន់ ។ ប្រសិនបើពុំអាចបង់បាន រដ្ឋបាលគយត្រូវទាមទារទៅអ្នកចេញការធានាឱ្យបង់ពន្ធ និងអាករ ។

**ប្រការ ៩**.-

រដ្ឋបាលគយត្រូវដោះបន្ទុកនិមុត្តិធានា ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពេលដែលមន្ត្រីគយមានសមត្ថកិច្ចពិនិត្យឃើញថា សិទ្ធិកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់ រាប់បញ្ចូលទាំងការបង់ពន្ធ និងអាករ ។

**ប្រការ ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១១ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១១
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ